ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ....................សហវ.......

# របាយការណ៍

# និន្នាការសេដ្ឋកិច្ច-សង្គម

## ប្រចាំខែ មីនា ឆ្នាំ ២០២៤

# Socio-Economic Trends Report

## March 2024


រៀបចំដោយ
នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច
អគ្គនាយកដ្ឋានគោលនយោបាយ
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ




# មាតិកា


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប /Executive summary** | **១** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា /Cambodia economic trends** | **៤** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ /Consumer price index | ៤ |
| ១.២. វិស័យពាណិជ្ជកម្ម /Trade | ៥ |
| ១.៣. វិស័យវិនិយោគឯកជន /Private investment | ៨ |
| ១.៤. វិស័យទេសចរណ៍ /Tourism | ៩ |
| ១.៥. វិស័យសំណង់ /Construction | ១០ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗ /Commodity prices** | **១១** |
| ២.១. ថ្លៃប្រេង (Crude oil price: Brent, WTI) | ១១ |
| ២.២. ថ្លៃអង្ករ (Rice price: 5% broken) | ១២ |
| **៣. ឧបសម្ព័ន្ធ** | **១៤** |

## ខ្លឹមសារសង្ខេប / Executive summary

*តាមរយៈការតាមដានសូចនាករសេដ្ឋកិច្ច-សង្គមសំខាន់ៗ ក្នុងខែមីនា ឆ្នាំ២០២៤ នេះ មាននិន្នាការដូចខាងក្រោម៖*

**១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មនៅរាជធានីភ្នំពេញក្នុងខែមីនា ឆ្នាំ២០២៤ គឺ ០,០៣% ធៀបនឹងខែមីនា ឆ្នាំ២០២៣ (ឆ្នាំធៀបឆ្នាំ)** ក្នុងនោះក្រុមសន្ទស្សន៍ថ្លៃទំនិញ និងសេវាកម្មសំខាន់ៗដែលមានការកើនឡើងរួមមាន៖ សន្ទស្សន៍ថ្លៃក្រុមការសិក្សា កើនឡើង ១,៦%, សន្ទស្សន៍ថ្លៃក្រុមសំលៀកបំពាក់និងស្បែកជើង កើនឡើង ១,២%, សន្ទស្សន៍ថ្លៃក្រុមផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈ កើនឡើង ០,៣%, និងសន្ទស្សន៍ថ្លៃក្រុមដឹកជញ្ជូន កើនឡើង ០,១%។

**២. ទំហំពាណិជ្ជកម្មក្នុងខែមីនា ឆ្នាំ២០២៤ មានកំណើនគួរឱ្យកត់សម្គាល់។** ទំហំពាណិជ្ជកម្មដកមាសសរុបក្នុងខែមីនា ឆ្នាំ២០២៤ សម្រេចបាន ៤ ៣៧៦ លានដុល្លារ កើនឡើងប្រមាណ ៧,៧% ធៀបនឹងខែមុន (ការនាំចេញកើនឡើង ១២,៨% និងនាំចូល កើនឡើង ២,៧%)។ ជាលទ្ធផល ក្នុងត្រីមាសទីមួយឆ្នាំ២០២៤ ទំហំពាណិជ្ជកម្មដកមាសសរុបសម្រេចបាន ១២ ៤៩៧ លានដុល្លារ កើនឡើងក្នុងរង្វង់ ១១,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣។

**៣. ក្នុងខែមីនា ឆ្នាំ២០២៤ ចំនួនភ្ញៀវទេសចរមានកំណើនល្អប្រសើរធៀបនឹងឆ្នាំមុន ជាពិសេសចំនួនភ្ញៀវចូលទស្សនាតំបន់អង្គរ។** ជាក់ស្តែង ក្នុងខែមីនា ឆ្នាំ២០២៤ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិចំនួន ៥៩៤ ១០២ នាក់ កើនឡើង ៣០,៨% ធៀបនឹងខែមីនា ឆ្នាំ២០២៣ និងចំនួនភ្ញៀវអន្តរជាតិទិញសំបុត្រពីគ្រឹះស្ថានអង្គរមានចំនួន ១១១ ៦៨៤ នាក់ កើនឡើង ៤០,៧ % ធៀបនឹងខែមីនា ឆ្នាំ២០២៣។

**៤. ក្នុងខែមីនា ឆ្នាំ២០២៤ ចំនួនគម្រោងសាងសង់រើបឡើងវិញបន្តិចធៀបនឹងខែមុន ខណៈដែលផ្ទៃក្រឡាសាងសង់មានការធ្លាក់ចុះ។** ក្នុងខែមីនាឆ្នាំ២០២៤ គម្រោងសំណង់ទទួលបានការអនុញ្ញាតសាងសង់សរុបមាន ២៩៧ គម្រោង កើនឡើង ១០,៤% និងមានផ្ទៃក្រឡា ៤៣៩ ពាន់ម៉ែត្រការ៉េ ថយចុះ ៤៥,៩% ធៀបនឹងខែមុន។

**៥. ស្ថានភាពគម្រោងវិនិយោគឯកជនដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងខែមីនា ឆ្នាំ២០២៤ មានបរិមាណប្រហាក់ប្រហែលនឹងខែមុន, ខណៈដែល ទុនវិនិយោគបានធ្លាក់ចុះធៀបនឹងខែមុន។** ជាក់ស្តែង ចំនួនគម្រោងវិនិយោគក្នុងខែមីនា ឆ្នាំ២០២៤ មាន ៣៧ គម្រោង ដែលបានប្រើប្រាស់ទុនវិនិយោគសរុបចំនួន ៨១៧ លានដុល្លារ ធ្លាក់ចុះ ៣១,៧% និងបង្កើតការងារថ្មីចំនួន ៣៩ ៩២២ កន្លែង កើនឡើង ៤,១% ធៀបនឹងខែមុន។

**៦. ក្នុងខែមីនា ឆ្នាំ២០២៤, នៅលើទីផ្សារកម្ពុជា ថ្លៃអង្ករជាមធ្យម និងថ្លៃប្រេងឥន្ទនៈជាមធ្យម មាននិន្នាការថយចុះ ១,៣% និង ១,៦% រៀងគ្នា ធៀបនឹងខែមុន, ខណៈដែលនៅលើទីផ្សារអន្តរជាតិ ថ្លៃអង្ករជាមធ្យមថយចុះ ២,៥% ប៉ុន្តែថ្លៃប្រេងឆៅជាមធ្យមកើនឡើង ៣,៧%។** ជាលទ្ធផល ក្នុងត្រីមាសទី១ ឆ្នាំ២០២៤, ថ្លៃអង្ករក្នុងស្រុក, ថ្លៃអង្ករនៅលើទីផ្សារអន្តរជាតិ, និងថ្លៃប្រេងឆៅអន្តរជាតិ កើនឡើង ១១,៥%, ៣០%, និង ១,៩% រៀងគ្នា ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣ ខណៈដែលថ្លៃប្រេងឥន្ទនៈក្នុងស្រុក ថយចុះ ២,៦%។ គួរកត់សម្គាល់ដែរថា ការកើនឡើងនៃថ្លៃប្រេងឆៅអន្តរជាតិអាចបណ្តាលមកពីភាពតានតឹងនៃជម្លោះនៅមជ្ឈិមបូព៌ា គួបផ្សំនឹងការវាយប្រហារពោងចក្រចំរាញ់ប្រេងឆៅរបស់ប្រទេសរុស្ស៊ី ជាបន្តបន្ទាប់ដោយខ្លួនប្រទេសអ៊ុយក្រែន។

*សូចនាករសេដ្ឋកិច្ចសំខាន់ៗក្នុងខែមីនា និងត្រីមាសទី១ ឆ្នាំ២០២៤ បានបង្ហាញពីសញ្ញាណកាន់តែល្អជាបន្តបន្ទាប់ ជាពិសេសលើវិស័យពាណិជ្ជកម្មអន្តរជាតិ និងទេសចរណ៍ ស្របពេលដែលស្ថានភាពអតិផរណាកំពុងវិលត្រលប់មកស្ថានភាពល្អប្រសើរឡើងវិញ, ប៉ុន្តែសកម្មភាពសាងសង់មានការធ្លាក់ចុះបន្តិច។ ផ្អែកលើការតាមដានជាប់ជាប្រចាំទាំងសេដ្ឋកិច្ចក្នុងប្រទេស និងសេដ្ឋកិច្ចសកល សកម្មភាពសេដ្ឋកិច្ចកម្ពុជា នឹងរើបឡើងវិញជាបណ្តើរៗជាពិសេសក្នុងវិស័យសេវាកម្ម និងកសិកម្ម។*

| តារាង ១៖ ស្ថិតិសង្ខេបសេដ្ឋកិច្ចតាមវិស័យ ប្រចាំខែមីនា ឆ្នាំ២០២៤ | | | | | | |
|---|---|---|---|---|---|---|
| | | ឯកតា | តម្លៃ | កើន/ថយ | | |
| | | | | ខែមុន | មីនាឆ្នាំមុន | ៣ខែ ដើមឆ្នាំមុន |
| I | **សន្ទស្សន៍ថ្លៃ និងថ្លៃទំនិញ** | | | | | |
| | -សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មនៅរាជធានីភ្នំពេញ | សន្ទស្សន៍ | 200.03 | 0.45% | 0.03% | -0.25% |
| | -សន្ទស្សន៍ថ្លៃម្ហូបអាហារ | សន្ទស្សន៍ | 252.08 | 0.70% | 0.01% | -0.21% |
| | -ថ្លៃប្រេងសាំង | រៀល/លីត្រ | 4,300 | -0.77% | 1.18% | -1.03% |
| | -ថ្លៃប្រេងម៉ាស៊ូត | រៀល/លីត្រ | 4,167 | -2.34% | 0.00% | -4.19% |
| | -ថ្លៃអង្ករផ្កាម្លិះ | រៀល/គ.ក | 3,803 | -2.39% | 3.72% | 5.52% |
| | -ថ្លៃអង្ករផ្កាខ្ញី | រៀល/គ.ក | 3,342 | -1.16% | 24.90% | 26.43% |
| | -ថ្លៃអង្ករនាងមិញ | រៀល/គ.ក | 2,971 | 0.09% | 4.58% | 5.35% |
| | -ថ្លៃសាច់ត្រី | រៀល/គ.ក | 10,965 | -1.47% | 4.49% | 6.93% |
| | -ថ្លៃសាច់ជ្រូក | រៀល/គ.ក | 24,575 | -0.88% | 6.73% | 8.38% |
| | -ថ្លៃប្រេងឆៅ (Brent) | USD/BBL | 85.45 | 2.01% | 8.81% | 2.09% |
| | -ថ្លៃប្រេងឆៅ (WTI) | USD/BBL | 80.49 | 4.94% | 9.70% | 1.23% |
| | -ថ្លៃអង្ករថៃ (ប្រភេទអង្ករបាក់ ៥%) | USD/MT | 613.00 | -1.76% | 28.78% | 27.74% |
| | -ថ្លៃអង្ករវៀតណាម (ប្រភេទអង្ករបាក់ ៥%) | USD/MT | 585.43 | -4.69% | 31.66% | 36.86% |
| II | **ពាណិជ្ជកម្មកម្ពុជា** | | | | | |
| | ***ការនាំចេញទំនិញសរុប (ដកមាស)*** | **លានដុល្លារ** | 2,276.17 | 12.77% | 10.58% | 17.98% |
| | -ផលិតផលវាយនភណ្ឌ | លានដុល្លារ | 1,002.48 | 7.88% | 17.67% | 20.64% |
| | -ផលិតផលមិនមែនវាយនភណ្ឌ | លានដុល្លារ | 1,273.70 | 16.94% | 5.58% | 15.78% |
| | -ក្នុងនោះ ផលិតផលកសិកម្ម* | លានដុល្លារ | 498.75 | 60.75% | -11.65% | -11.81% |
| | ***ការនាំចូលសរុប (ដកមាស)*** | **លានដុល្លារ** | 2,099.75 | 2.68% | -8.61% | 6.39% |
| | -ប្រេងឥន្ធនៈ | លានដុល្លារ | 236.30 | -6.76% | 22.90% | 23.49% |
| | -វត្ថុធាតុដើមកាត់ដេរ | លានដុល្លារ | 3,611.49 | -2.08% | -18.61% | 9.97% |
| | -គ្រឿងសំណង់** | លានដុល្លារ | 155.35 | -10.79% | -1.20% | 22.86% |
| | -វត្ថុធាតុដើមកសិកម្ម (ជីកសិកម្ម) | លានដុល្លារ | 19.25 | 7.28% | 4.98% | 25.60% |
| | -គ្រឿងហូបចុក (Food stuff) | លានដុល្លារ | 62.44 | 8.86% | 1.68% | 6.06% |
| III | **ទេសចរ** | | | | | |
| | -ភ្ញៀវទេសចរអន្តរជាតិ | នាក់ | 594,102.00 | 32.46% | 30.83% | 22.54% |
| | -ភ្ញៀវទេសចរក្នុងស្រុក | នាក់ | 1,094,242.00 | -14.99% | 54.95% | 8.02% |
| | -ភ្ញៀវទេសចរអន្តរជាតិទិញសំបុត្រពីគ្រឹះស្ថានអង្គរ | នាក់ | 111,684.00 | -7.18% | 40.68% | 47.05% |
| IV | **សាងសង់** | | | | | |
| | -ចំនួនគម្រោងដែលទទួលបានការអនុញ្ញាតសាងសង់ | គម្រោង | 297.00 | 10.41% | 6.83% | -18.87% |
| | -ផ្ទៃក្រឡាសាងសង់ | ម៉ែត្រការ៉េ | 439,151.00 | -45.94% | -65.07% | -34.75% |
| | -ទំហំទឹកប្រាក់សាងសង់ | លានដុល្លារ | 185,719,894.00 | -39.05% | -61.51% | -38.75% |
| V | **គម្រោងវិនិយោគ** | | | | | |
| | -គម្រោងវិនិយោគឯកជន | គម្រោង | 37.00 | 0.00% | 362.50% | 171.79% |
| | -ទុនវិនិយោគសរុប | លានដុល្លារ | 817.90 | -31.77% | 1158.00% | 649.46% |
| | -កម្លាំងពលកម្មថ្មី | នាក់ | 39,922.00 | 4.11% | 482.21% | 128.81% |

***សម្គាល់*** ៖ *ផលិតផលកសិកម្ម រួមមាន៖ ស្រូវ, ដំឡូងមី, ពោត, សណ្តែក, ចេក, ស្វាយ, ស្វាយចន្ទី, កៅស៊ូ, ស្ករ, ផលិតផលជលផល និងផលិតផលកសិកម្មផ្សេងទៀត

**សំណង់ រួមមាន៖ គ្រឿងបរិក្ខារសំណង់, ស៊ីម៉ង់ និងដែកថែប។

# ១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends

## ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index

តាមរយៈទិន្នន័យផ្លូវការពីវិទ្យាស្ថានជាតិស្ថិតិក្នុងខែមីនា ឆ្នាំ២០២៤, សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្ម នៅរាជធានីភ្នំពេញ កើនឡើង ០,៥% ធៀបនឹងខែមុន និងកើនឡើង ០,០៣% ធៀបនឹងខែមីនា ឆ្នាំ២០២៣។ ក្នុងខែមីនា ឆ្នាំ២០២៤ ស្ថានភាពអតិផរណាប្រទេសកម្ពុជាបានវិលត្រលប់មករកស្ថានភាពល្អប្រសើរជាបណ្តើរៗហើយ ដែលកំណើននេះ រួមចំណែកដោយការកើនឡើងនៃក្រុមសន្ទស្សន៍ថ្លៃទំនិញនិងសេវាកម្ម (ឆ្នាំធៀបឆ្នាំ) សំខាន់ៗមួយចំនួន រួមមាន៖ (១). សន្ទស្សន៍ថ្លៃម្ហូបអាហារ កើនឡើង ០,០១% ក្នុងនោះ សន្ទស្សន៍ថ្លៃអង្ករ កើនឡើង ០,១% និងសន្ទស្សន៍ថ្លៃផ្លែឈើ កើនឡើង ០,៤%, (២). សន្ទស្សន៍ថ្លៃក្រុមការសិក្សា កើនឡើង ១,៦%, (៣). សន្ទស្សន៍ថ្លៃក្រុមសំលៀកបំពាក់ និងស្បែកជើង កើនឡើង ១,២%, និង(៤).សន្ទស្សន៍ថ្លៃក្រុមផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈ កើនឡើង ០,៣%។

ជាមួយគ្នានេះ សន្ទស្សន៍ថ្លៃក្រុមដឹកជញ្ជូន (ឆ្នាំធៀបឆ្នាំ) កើនឡើង ០,១% ស្របពេលដែល ថ្លៃប្រេងសាំងធម្មតា កើនឡើង ១,២% ធៀបនឹងខែមីនា ឆ្នាំ២០២៣ និងថ្លៃប្រេងម៉ាស៊ូត (ដូចមុន)។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ*




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងពាណិជ្ជកម្ម*

## ១.២. វិស័យពាណិជ្ជកម្ម / Trade

ទំហំពាណិជ្ជកម្មសរុបដកមាសក្នុងខែមីនា ឆ្នាំ២០២៤ សម្រេចបានកំណើនល្អគួរឱ្យកត់សម្គាល់ ទាំងកំណើនធៀបខែមុន, ធៀបខែមីនាឆ្នាំមុន និងធៀបត្រីមាសទី១ឆ្នាំមុន។ ជាក់ស្តែង ទំហំពាណិជ្ជកម្មក្នុងខែនេះ សម្រេចបានទំហំ ៤ ៣៧៦ លានដុល្លារ កើនឡើង ៧,៧% ធៀបនឹងខែមុន, និងកើនឡើង ០,៥% ធៀបនឹងខែមីនាឆ្នាំមុន។ បន្ថែមលើនេះ ក្នុងត្រីមាសទី១ ឆ្នាំ២០២៤នេះ ទំហំពាណិជ្ជកម្មដកមាសសរុបមានទំហំ ១២ ៤៩៧ លានដុល្លារ កើនឡើង ១១,៩% ធៀបនឹងត្រីមាសទី១ ឆ្នាំមុន។ គួរឱ្យកត់សម្គាល់ផងដែរ តុល្យភាពជញ្ជីងពាណិជ្ជកម្ម (នាំចេញ-នាំចូលដកមាស) ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ បានបង្ហាញពីសញ្ញាល្អ ដែលសម្រេចបានអតិរេកប្រមាណជាង ២៧ លានដុល្លារ។ ក្នុងន័យនេះ អាចបញ្ជាក់បានថា កម្ពុជាបានកាត់បន្ថយការពឹងផ្អែកលើទំនិញនាំចូលពីក្រៅប្រទេស មកពឹងកាន់តែច្រើនលើផលិតផលដែលមាននៅក្នុងស្រុក។




*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

### ក. ការនាំចេញ៖

ការនាំចេញទំនិញដកមាសក្នុងខែមីនា ឆ្នាំ២០២៤ នេះ មានទំហំ ២ ២៧៦ លានដុល្លារ ដែលជាទំហំនាំចេញប្រចាំខែខ្ពស់បំផុត ក្នុងរយៈពេល ២០ខែចុងក្រោយនេះ។ ទំហំនេះ កើនឡើង ១២,៨% ធៀបនឹងខែមុន ដែលជំរុញដោយកំណើនល្អប្រសើរនៃការនាំចេញផលិតផលកាត់ដេរ (កើនឡើង ៧,៩%) និងកម្មន្តសាលមិនមែនកាត់ដេរ (កើនឡើង ១៦,៩%) ដែលមានដូចជា កសិផល គ្រឿងសង្ហារិម កង់ និងប្រភេទខ្សែចម្លងនិងអ៊ុបទិក ជាដើម។ ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០២៣ មក រចនាសម្ព័ន្ធនៃការនាំចេញទំនិញរបស់កម្ពុជា បានប្តូរពីការពឹងផ្អែកលើការនាំចេញផលិតផលកាត់ដេរ មកជាការនាំចេញកម្មន្តសាលមិនមែនកាត់ដេរជំនួសវិញ។ ជាក់ស្តែង គិតត្រឹម ៣ខែដើមឆ្នាំ២០២៤ នេះ ចំណែកនៃការនាំចេញកម្មន្តសាលមិនមែនកាត់ដេរមានប្រមាណជាង ៥៣,២% ខណៈដែលការនាំចេញផលិតផលកាត់ដេរមានត្រឹម ៤៥,៩% នៃទំហំនាំចេញសរុប ដែលការណ៍នេះ បង្ហាញថាផលិតផលមិនមែនកាត់ដេរបានប្រែក្លាយទៅជាជន្ទល់ដ៏សំខាន់ក្នុងការទ្រទ្រង់កំណើននៃការនាំចេញរបស់កម្ពុជា។ គួរឱ្យកត់សម្គាល់ផងដែរ ការនាំចេញកសិផលក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤ នេះ បានបង្ហាញពីសន្ទុះគួរឱ្យកត់សម្គាល់នៃកំណើនកសិផលយុទ្ធសាស្ត្រ មានជាអាទ៍ អង្ករ កៅស៊ូ ស្វាយចន្ទី និងដំឡូងមី ខណៈដែល កសិផលផ្សេងទៀតបានធ្លាក់ចុះវិញ ធៀបនឹងរយៈពេល ៣ខែដើមឆ្នាំមុន។ យ៉ាងណាមិញ, បើទោះបីជាការនាំចេញសូឡា ហាក់បានបង្ហាញពីការធ្លាក់ចុះគួរឱ្យបារម្ភបន្តិចក្តី ប៉ុន្តែការណ៍នេះរំពឹងថា

នឹងសម្រេចបានកំណើនល្អឡើងវិញនាខែបន្តបន្ទាប់ខាងមុខ ដោយសារការនាំចូលសូឡាក្នុងរយៈពេល ៣ខែដើមឆ្នាំនេះ កើនឡើង ៨៨% ធៀបនឹងរយៈពេល ៣ខែដើមឆ្នាំមុន។

*ក្រាហ្វិច ៣៖ ទំហំទឹកប្រាក់នាំចេញដកមាសគិតត្រឹមខែមីនា ឆ្នាំ២០២៤ (គិតជាលានដុល្លារ)*




*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

ចាប់តាំងពីដើមឆ្នាំ២០២៤ មក ការនាំចេញទៅកាន់ទីផ្សារសំខាន់ៗ បានបង្ហាញពីប្រក្រតីភាពនៃកំណើនល្អប្រសើរជាបន្តបន្ទាប់។ ជាក់ស្តែង ក្នុងខែមីនា ឆ្នាំ២០២៤ នេះ ការនាំចេញទៅកាន់ទីផ្សារអាស៊ាន តំបន់អឺរ៉ុប សហរដ្ឋអាម៉េរិក ចិន ជប៉ុន អង់គ្លេស និងប្រទេសដទៃទៀត សម្រេចបានកំណើនល្អប្រសើរ ធៀបនឹងខែមុន។ បន្ថែមលើនេះ គិតត្រឹមត្រីមាសទី១ ឆ្នាំ២០២៤ ការនាំចេញទៅកាន់ទីផ្សារតំបន់អាស៊ាន មានទំហំ ១ ៧៧២ លានដុល្លារ កើនឡើង ៣៣,១%, ទីផ្សារអឺរ៉ុប មានទំហំ ៩០៣ លានដុល្លារ កើនឡើង ១១,៩%, ទីផ្សារចិន ៣៦៦ លានដុល្លារ កើនឡើង ១១,៤%, ទីផ្សារជប៉ុន មានទំហំ ៣៦៥ លានដុល្លារ កើនឡើង ១៨,៤%, ទីផ្សារអង់គ្លេស មានទំហំ ២០៩ លានដុល្លារ កើនឡើង ២៧,៤%, ទីផ្សារប្រទេសផ្សេងទៀត មានទំហំ ៧១៥ លានដុល្លារ កើនឡើង ១៣,៦% ធៀបនឹងត្រីមាសទី១ ឆ្នាំមុន។

*ក្រាហ្វិច ៤៖ ទីផ្សារអាស៊ាន អាម៉េរិក និងអឺរ៉ុប ជាទីផ្សារនាំចេញធំ របស់កម្ពុជាក្នុងខែមីនា*




*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

តារាង ២. ទំហំទឹកប្រាក់ និងចំណែក% នៃនាំចេញតាមមុខទំនិញសំខាន់ៗ ក្នុងរយៈពេល ៣ខែ ដើមឆ្នាំ២០២៤ (គិតជាលានដុល្លារអាម៉េរិក)

| ទំនិញ (គិតជាលានដុល្លារ) | ទំហំទឹកប្រាក់នាំចេញ | សមាមាត្រជាភាគរយ |
|---|---|---|
| វាយនភណ្ឌ | 2,898 | 45.9% |
| កង់ | 69 | 1.1% |
| អង្ករ | 134 | 2.1% |
| ដំឡូងមី | 422 | 6.7% |
| ជ័រកៅស៊ូ | 128 | 2.0% |
| ទំនិញផ្សេងៗ | 2,611 | 41.3% |
| សរុបដកមាស | 6,262 | 99.1% |
| ទំនិញនាំចេញដកមាសមាន ៩៩,១% នៃទំនិញនាំចេញសរុប | | |

*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

**<u>ខ. ការនាំចូល</u>** ៖ ការនាំចូលទំនិញដកមាស ក្នុងខែមីនា ឆ្នាំ២០២៤ សម្រេចបានកំណើនល្អប្រសើរធៀបនឹងខែមុនៗនៃដើមឆ្នាំ២០២៤។ ជាក់ស្ដែង ក្នុងខែនេះ ការនាំចូលទំនិញដកមាស សម្រេចបានទំហំប្រមាណជាង ២ ១០០ លានដុល្លារ កើនឡើង ២,៧% ធៀបនឹងខែមុន ដែលជំរុញកំណើនដោយការនាំចូលភេសជ្ជៈ, ម្ហូបអាហារ, គ្រឿងម៉ាស៊ីន (អេឡិចត្រូនិក), សម្លៀកបំពាក់ និងទំនិញនាំចូលផ្សេងៗ។ ដោយឡែក, ការនាំចូលផលិតផលមួយចំនួនទៀត បានបង្ហាញពីការធ្លាក់ចុះ ដែលរួមមាន ក្រណាត់ គ្រឿងសំណង់, ឧបករណ៍អេឡិចត្រូនិក, យានយន្ត និងផលិតផលឥន្ធនៈ។ គិតត្រឹមត្រីមាសទី១ ឆ្នាំ២០២៤ ការនាំចូលទំនិញដកមាស សម្រេចបាន ៦ ២៣៥ លានដុល្លារ កើនឡើង ៦,៤% ធៀបនឹងត្រីមាសទី១ ឆ្នាំមុន ក្នុងនោះ ទំនិញនាំចូលសំខាន់ៗ មានកំណើនល្អប្រសើរ ខណៈដែលការនាំចូលគ្រឿងម៉ាស៊ីន (អេឡិចត្រូនិក), យានយន្ត និងទំនិញនាំចូលផ្សេងៗ បានធ្លាក់ចុះ។

ក្រាហ្វិច ៥៖ ទំហំទឹកប្រាក់នាំចូលដកមាសក្នុងខែមីនា (គិតជាលានដុល្លារ) និងកំណើនធៀបខែ ធៀបឆ្នាំ




*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

គួរឱ្យកត់សម្គាល់ផងដែរ ការនាំចេញទៅកាន់ទីផ្សារសំខាន់ៗ បានបង្ហាញពីប្រក្រតីភាពនៃកំណើនល្អប្រសើរ ខណៈដែល ការនាំចូលមកពីទីផ្សារធំៗ (អាស៊ាន និងចិន) មានការថមថយបន្តិច។ ការនាំចេញទៅទីផ្សារសំខាន់ៗ ក្នុងខែមីនា ឆ្នាំ២០២៤ នេះ មានកំណើនល្អប្រសើរ ពោលគឺ ការនាំចេញទៅកាន់ទីផ្សារអាស៊ាន តំបន់អឺរ៉ុប សហរដ្ឋអាម៉េរិក ចិន ជប៉ុន អង់គ្លេស និងប្រទេសដទៃទៀត កើនឡើង ២៧,៦%, ៧,៥%, ៣០,៦%, ៦,៣%, ៤,៧%, និង ៥,៦% រៀងគ្នាធៀបនឹងខែមុន។ ចំណែកឯ ការនាំចូលពីទីផ្សារអាស៊ាន ធ្លាក់ចុះ ១,៨% និងចិន ធ្លាក់ចុះ ៧,៨% ខណៈដែលការនាំចូលពីទីផ្សារអឺរ៉ុប ជប៉ុន អង់គ្លេស និងប្រទេសដទៃទៀត កើនឡើង ១៩០,៩%, ១៦,៥%, ១៧០,២%, និង ១៤,១% រៀងគ្នាធៀបនឹងខែមុន។

*ក្រាហ្វិច ៦៖ ទីផ្សារអាស៊ាន ចិននិង អឺរ៉ុប បានរួមចំណែកធំ ក្នុងទីផ្សារនាំចូលសរុបរបស់កម្ពុជាក្នុងខែមីនា*




*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

តារាង ៣. ទំហំទឹកប្រាក់ និងចំណែក% នៃនាំចូលតាមមុខទំនិញសំខាន់ៗ ក្នុងរយៈពេល ៣ខែ ដើមឆ្នាំ២០២៤ (គិតជាលានដុល្លារអាម៉េរិក)

| **ទំនិញ (គិតជាលានដុល្លារ)** | **ទំហំទឹកប្រាក់នាំចេញ** | **សមាមាត្រជាភាគរយ** |
|---|---|---|
| ក្រណាត់ | 1,129 | 17.7% |
| គ្រឿងសំណង់ | 513 | 8.0% |
| យានយន្ត | 279 | 4.4% |
| ប្រេងឥន្ធនៈ | 722 | 11.3% |
| ទំនិញផ្សេងទៀត | 3,593 | 56.2% |
| សរុបដកមាស | 6,235 | 97.6% |
| ទំនិញនាំចូលដកមាសមាន ៩៧.៦% នៃទំនិញនាំចូលសរុប | | |

*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

## ១.៣. ស្ថានភាពវិនិយោគ / Investment

នៅក្នុងខែមីនា ឆ្នាំ២០២៤ ប្រទេសកម្ពុជាទទួលបានគម្រោងវិនិយោគសរុប ៣៧ គម្រោង ដែលក្នុងនោះគម្រោងក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ១០ គម្រោង និងក្រៅតំបន់សេដ្ឋកិច្ចពិសេសមានគម្រោងថ្មីចំនួន ២៦ គម្រោង និងគម្រោងពង្រីកសង្វាក់ផលិតកម្ម ១ គម្រោង។ ការវិនិយោគនេះបានប្រើប្រាស់ទុនប្រមាណ ៨១៧,៩ លានដុល្លារ និងមានលទ្ធភាពបង្កើតការងារថ្មីចំនួន ៣៩ ៩២២ នាក់។ បើប្រៀបធៀបទៅនឹងខែមីនា ឆ្នាំ២០២៤ លទ្ធភាពបង្កើតការងារថ្មីកើនឡើង ៤,១%, ខណៈដែល ចំនួនគម្រោងមិនមានការប្រែប្រួល ស្របពេលដែល ទំហំទុន បានធ្លាក់ចុះប្រមាណ ៣១,៨%។

ស្ថានភាពវិនិយោគនៅតែមានសញ្ញាណល្អប្រសើរ ខណៈដែលចំនួនគម្រោងវិនិយោគ ទុនវិនិយោគ និងលទ្ធភាពបង្កើតការងារថ្មី កើនឡើង ៣៦២,៥%(ស្មើនឹង ២៩ គម្រោង), ១ ១៥៨,០% និង៤៨២,២%(ស្មើនឹង ៦០ ២៩៣ ការងារ)រៀងគ្នា ធៀបនឹងខែមីនា ឆ្នាំមុន។

ជាលទ្ធផល ក្នុងត្រីមាសទី១ឆ្នាំ២០២៤ មានគម្រោងវិនិយោគសរុប ១០៦ គម្រោង, ទុនសរុប ២ ២០៤ លានដុល្លារ និងលទ្ធភាពបង្កើតការងារថ្មី មាន ១០៧ ១០០ កន្លែង។ បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣ ចំនួនគម្រោងវិនិយោគ កើនឡើង ៦៧ គម្រោង (ស្មើនឹង ១៧២%), ទុនវិនិយោគ កើនឡើង ៦៥០%(ស្មើនឹង ១ ៩០៩ លានដុល្លារ), ការងារកើនឡើង ១២៩%(ស្មើនឹង ៦០ ២៩៣ ការងារ) រៀងគ្នា។

ក្រាហ្វិច ៧៖ ទុនវិនិយោគតាមវិស័យ ៣ខែ ដើមឆ្នាំ២០២៤




តារាង ៤៖ ស្ថានភាពវិនិយោគសរុប ឆ្នាំ២០២១, ២០២២, ២០២៣, និង ២០២៤

| អំឡុងពេល | ចំនួនគម្រោងវិនិយោគ | ទំហំទុនវិនិយោគ (លានដុល្លារ) | ការបង្កើតការងារថ្មី |
|---|---|---|---|
| ៣ខែ ឆ្នាំ២០២១ | 49 | 2,207 | 8,364 |
| ៣ខែ ឆ្នាំ២០២២ | 47 | 2,521 | 37,406 |
| ៣ខែ ឆ្នាំ២០២៣ | 39 | 294 | 46,807 |
| ៣ខែ ឆ្នាំ២០២៤ | 106 | 2,204 | 107,100 |

*ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)*

## ១.៤. ស្ថានភាពទេសចរណ៍ / Tourism

ក្នុងខែមីនា ឆ្នាំ២០២៤ ភ្ញៀវទេសចអន្តរជាតិមានចំនួន ៥៩៤ ១០២ នាក់ កើនឡើង ៣២,៥% ធៀបនឹងខែមុន ខណៈដែល ភ្ញៀវទេសចរក្នុងស្រុក មាន ១ ០៩៤ ២៤២ នាក់ ធ្លាក់ចុះ ១៥,០% និងភ្ញៀវអន្តរជាតិចូលទស្សនារមណីយដ្ឋានតំបន់អង្គរមាន ចំនួន ១១១ ៦៧៨ នាក់ ធ្លាក់ចុះ ៧,២%។ បើធៀបនឹងខែមីនា ឆ្នាំ២០២៣ ចំនួនភ្ញៀវទេសចអន្តរជាតិ, ភ្ញៀវទេសចរជាតិក្នុងស្រុក និង ភ្ញៀវបរទេសចូលទស្សនារមណីយដ្ឋានតំបន់អង្គរ មានកំណើន ៣០,៨%, ៥៥,០% និង៤០,៧% រៀងគ្នា។

ជាលទ្ធផល ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិសរុបចំនួន ១,៥៨ លាននាក់, ភ្ញៀវទេសចរជាតិចំនួន ៣,៨៧ លាននាក់ និង ភ្ញៀវបរទេសចូលទស្សនារមណីយដ្ឋានតំបន់អង្គរចំនួន ៣៤៧,៥៣ ពាន់នាក់ កើនឡើង ២២,៥%, ៨,០% និង ៤៧,១% រៀងគ្នា។

ក្រាហ្វិច ៨៖ ចំនួនភ្ញៀវទេសចរនៅកម្ពុជាគិតត្រឹមខែមីនា ឆ្នាំ២០២៤




*ប្រភព៖ ក្រសួងទេសចរណ៍*

## ១.៥. ស្ថានភាពសំណង់ / Construction

ក្នុងខែមីនា ឆ្នាំ២០២៤ គម្រោងដែលទទួលបានការអនុញ្ញាតសាងសង់សរុប ២៩៧ គម្រោង ដែលមានផ្ទៃក្រឡាសរុប ៤៣៩ ពាន់ម៉ែត្រការ៉េ និងបានប្រើប្រាស់ទុនក្នុងទំហំ ១៨៥ លានដុល្លារ។ បើធៀបនឹងខែមុន វិស័យសំណង់បានធ្លាក់ចុះ ដោយផ្ទៃក្រឡាសាងសង់ និងទំហំទឹកប្រាក់សាងសង់ បានធ្លាក់ចុះ ៤៦% និង ៣៩% រៀងគ្នា ខណៈដែល ចំនួនគម្រោងសាងសង់មានការកើនឡើងប្រមាណ ២១ គម្រោង ស្មើនឹង ១០,៤%។

យោងតាមទិន្នន័យ ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ គម្រោងទទួលបានការអនុញ្ញាតសាងសង់សរុប មានចំនួន ៨៣០ គម្រោង ក្នុងនោះ មានគម្រោងលំនៅដ្ឋាន ៧០៥ គម្រោង (មានបុរីចំនួន ៦៧៣ គម្រោង និងខុនដូ ៣២ គម្រោង), សំណង់ឧស្សាហកម្ម ៤៣ គម្រោង, សំណង់ពាណិជ្ជកម្ម ៤៧ គម្រោង, សំណង់ទេសចរណ៍ ១៣ គម្រោង, និង សំណង់សាធារណៈ ២១ គម្រោង។

ក្រាហ្វិច១០៖ ផ្ទៃក្រឡាសាងសង់សរុបនិងអត្រាបម្រែបម្រួលក្នុងរយៈពេល ៣ខែ ចាប់គិតពី ២០២០-២០២៤




ក្រាហ្វិច១១៖ ចំនួនសំណើរសាងសង់សរុបនិងអត្រាបម្រែបម្រួលក្នុងរយៈពេល ៣ខែ ចាប់គិតពី ២០២០-២០២៤






ក្រាហ្វិច ១២៖ ចំនួនគម្រោងនិងក្រឡាផ្ទៃ (ម៉ែត្រការ៉េ)

*ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

## ២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity prices

### ២.១. ថ្លៃប្រេងឥន្ធនៈ៖

នៅលើទីផ្សារកម្ពុជា ថ្លៃប្រេងឥន្ធនៈជាមធ្យម (ប្រេងសាំងធម្មតា និងប្រេងម៉ាស៊ូត) ក្នុងខែមីនា ឆ្នាំ២០២៤ ថយចុះ ១,៦% ធៀបនឹងខែមុន ក្នុងនោះ ប្រេងសាំងធម្មតាថ្លៃ ៤ ៣០០ រៀល/លីត្រ (ទាបជាងខែមុន ០,៨%) និងប្រេងម៉ាស៊ូតថ្លៃ ៤ ១៦៧ រៀល/លីត្រ (ទាបជាងខែមុន ២,៣%)។ គួរកត់សម្គាល់ដែរថា ក្នុងខែមីនា ឆ្នាំ២០២៤ ខណៈដែលថ្លៃប្រេងអន្តរជាតិមាននិន្នាការកើនឡើង, ថ្លៃប្រេងឥន្ធនៈក្នុងស្រុកនៅមិនទាន់មានការកើនឡើងគួរឱ្យកត់សម្គាល់នៅឡើយទេ។ ការណ៍នេះអាចបណ្តាលមកពីការថមថយការធ្វើដំណើរកំសាន្តក្នុងស្រុកដោយសារអាកាសធាតុក្តៅខ្លាំង គួបផ្សំនឹងការកើនឡើងបរិមាណនាំចូលប្រេងឥន្ធនៈនៅដើមឆ្នាំ២០២៤។ យោងតាម ទិន្នន័យរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ ការនាំចូលប្រេងសាំងធម្មតា និងប្រេងម៉ាស៊ូត កើនឡើង ៣១,២% និង ៣១,៦% រៀងគ្នា ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ជាលទ្ធផល ក្នុងត្រីមាសទី១ ឆ្នាំ២០២៤, ថ្លៃប្រេងសាំងធម្មតាជាមធ្យម និងថ្លៃប្រេងម៉ាស៊ូតជាមធ្យម ថយចុះ ១,០% និង ៤,២% រៀងគ្នា ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣។

ក្នុងខែមីនា ឆ្នាំ២០២៤ ថ្លៃប្រេងឆៅគិតជាមធ្យមនៅលើទីផ្សារអន្តរជាតិស្ថិតក្នុងរង្វង់ ៨៣,៦ ដុល្លារ/បារ៉ែល កើនឡើង ៣,៧% ធៀបនឹងខែមុន ក្នុងនោះ ប្រេងឆៅប្រភេទ Brent ថ្លៃ ៨៥,៥ ដុល្លារ/បារ៉ែល (ខ្ពស់ជាងខែមុន ២,០%) និងប្រេងឆៅប្រភេទ WTI ថ្លៃ ៨០,៥ ដុល្លារ/បារ៉ែល (ខ្ពស់ជាងខែមុន ៤,៩%)។ គួរកត់សម្គាល់ដែរថា ថ្លៃប្រេងឆៅអន្តរជាតិមាននិន្នាការកើនឡើងជាបន្តបន្ទាប់ក្នុងរយៈពេល ៣ខែដើមឆ្នាំ២០២៤, ការណ៍នេះអាចបណ្តាលមកពីបញ្ហាមួយចំនួនមានជាអាទិ៍៖ (១).ការកាត់បន្ថយការផ្គត់ផ្គង់ប្រេងឆៅរបស់ OPEC+, (២).ការវាយប្រហារនៅតំបន់សមុទ្រក្រហម, (៣).ភាពតានតឹងនៃស្ថានភាពសង្គ្រាមនៅមជ្ឈិមបូព៌ា, និង(៤).ការវាយប្រហាររោងចក្រចំរាញ់ប្រេងរបស់ប្រទេសរុស្ស៊ីដោយឌ្រូនប្រទេសអ៊ុយក្រែន។ ជាលទ្ធផល ត្រីមាសទី១ ឆ្នាំ២០២៤, ថ្លៃប្រេងឆៅជាមធ្យម កើនឡើង ១,៩% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣។




*ប្រភព៖ ក្រសួងពាណិជ្ជកម្ម*




*ប្រភព៖ ធនាគារពិភពលោក (The Pink Sheet)*

## ២.២. ថ្លៃអង្ករ៖

ក្នុងខែមីនា ឆ្នាំ២០២៤ ថ្លៃអង្ករជាមធ្យមនៅលើទីផ្សារក្នុងស្រុកថយចុះ ១,៣% ធៀបនឹងខែមុន ក្នុងនោះ អង្ករផ្កាម្លិះថ្លៃ ៣ ៨០៣ រៀល/គ.ក្រ (ទាបជាងខែមុន ២,៤%) និងអង្ករផ្កាខ្ញីថ្លៃ ៣ ៣៤២ រៀល/គ.ក្រ (ទាបជាងខែមុន ១,២%) ដោយឡែក អង្ករនាងមិញថ្លៃ ២ ៩៧១ រៀល/គ.ក្រ (ខ្ពស់ជាងខែមុន ០,១%)។ ជាលទ្ធផល ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ ថ្លៃអង្ករជាមធ្យម កើនឡើង ១១,៦% ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៣។ ផ្អែកតាមការតាមដាន ថ្លៃអង្ករក្នុងស្រុកក្នុងត្រីមាសទី១ ឆ្នាំ២០២៤ ស្ថិតក្នុងរង្វង់ ៣ ៤០០ រៀល/គ.ក្រ មិនមានការប្រែប្រួលគួរឱ្យកត់សម្គាល់ឡើយ។

ក្នុងខែមីនា ឆ្នាំ២០២៤ ថ្លៃអង្ករជាមធ្យមនៅលើទីផ្សារអន្តរជាតិស្ថិតក្នុងរង្វង់ ៥៩៧,៥ ដុល្លារ/តោន ថយចុះ ២,៥% ធៀបនឹងខែមុន ក្នុងនោះ អង្ករថៃប្រភេទបាក់៥% ថ្លៃ ៦១៣ ដុល្លារ/តោន (ទាបជាងខែមុន ១,៨%), អង្ករវៀតណាមប្រភេទបាក់ ៥% ថ្លៃ ៥៨៥,៤ ដុល្លារ/តោន (ទាបជាងខែមុន ៤,៧%)។ ទោះបីជាថ្លៃអង្ករក្នុងត្រីមាសទី១ ឆ្នាំ២០២៤ មាននិន្នាការថយចុះជាបន្តបន្ទាប់, តែថ្លៃអង្ករជាមធ្យមក្នុងឆ្នាំ២០២៤ នៅខ្ពស់នៅឡើយធៀបនឹងឆ្នាំ២០២៣។ ជាក់ស្តែង

ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ ថ្លៃអង្ករជាមធ្យមលើទីផ្សារអន្តរជាតិ កើនឡើង ២៧,៩% ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៣ ក្នុងនោះ ថ្លៃអង្ករថៃប្រភេទបាក់ ៥% កើនឡើង ២៧,៧% និងថ្លៃអង្កររៀតណាមប្រភេទបាក់ ៥%កើនឡើង ៣៦,៩%។




*ប្រភព៖ ការចុះស្រង់ថ្លៃទំនិញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋានគោលនយោបាយពីផ្សារចំនួន ៤ ក្នុងរាជធានីភ្នំពេញ*




*ប្រភព៖ ធនាគារពិភពលោក (The Pink Sheet)*

**************

# ៣. ឧបសម្ព័ន្ធ

## ៣.១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia Economic Trends

### ៣.១.១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index

តារាង ៣.១.១៖ ការប្រែប្រួលសន្ទស្សន៍ថ្លៃនៃក្រុមទំនិញទាំង ១២ ក្នុងខែកុម្ភៈ ឆ្នាំ២០២៤ គិតជា%

| បរិយាយ | ២០២៣ | | ២០២៤ | | ២០២៣ | | ២០២៤ | |
|---|---|---|---|---|---|---|---|---|
| | ធៀបនឹងខែមុន (MoM) | | | | ធៀបនឹងឆ្នាំមុន (YoY) | | | |
| | កុម្ភៈ | មីនា | កុម្ភៈ | មីនា | កុម្ភៈ | មីនា | កុម្ភៈ | មីនា |
| **មុខទំនិញគ្រប់មុខ** | 0.5% | 0.1% | 0.7% | 0.5% | 2.2% | 0.7% | -0.3% | 0.0% |
| ១. អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | 0.4% | 0.4% | 0.5% | 0.7% | 3.1% | 2.4% | -0.3% | 0.0% |
| ២. ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | 0.1% | 0.2% | 0.2% | 0.1% | 1.2% | 1.1% | -0.1% | -0.2% |
| ៣. សំលៀកបំពាក់ និងស្បែកជើង | 0.3% | 0.3% | 0.6% | 0.9% | 2.8% | 2.0% | 0.5% | 1.2% |
| ៤. ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈដទៃទៀត | 0.4% | -0.1% | 0.5% | 0.3% | -0.2% | -3.0% | -0.1% | 0.3% |
| ៥. គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ | 0.1% | 0.1% | 0.2% | 0.3% | 1.7% | 0.9% | 0.1% | 0.2% |
| ៦. សុខាភិបាល | 0.1% | 0.1% | 0.3% | 0.3% | -0.1% | -0.3% | 0.0% | 0.2% |
| ៧. ការដឹកជញ្ជូន | 0.9% | -0.6% | 2.4% | -0.2% | 0.2% | -6.0% | -0.3% | 0.1% |
| ៨. គមនាគមន៍ | 0.1% | 0.0% | 0.1% | 0.0% | -0.3% | -0.4% | 0.0% | -0.1% |
| ៩. ការកំសាន្ត និងវប្បធម៌ | 0.6% | 0.4% | 0.6% | 0.6% | 2.8% | 2.3% | -0.2% | -0.1% |
| ១០. ការសិក្សា | 0.0% | 0.3% | 0.4% | 0.8% | 1.6% | 1.2% | 1.1% | 1.6% |
| ១១. ភោជនីយដ្ឋាន | 1.1% | -0.7% | 1.1% | -0.2% | 2.8% | 0.8% | -1.3% | -0.8% |
| ១២. ទំនិញ និងសេវាកម្មផ្សេងៗ | 0.2% | 0.3% | 0.4% | 0.3% | 1.4% | 1.3% | 0.3% | 0.3% |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (NIS)*
*សម្គាល់៖ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ៣.១.២. វិស័យពាណិជ្ជកម្ម / Trade

តារាង ៣.១.២.៖ ការនាំចេញ និងការនាំចូលតាមមុខទំនិញសំខាន់ៗប្រចាំខែមីនា ឆ្នាំ២០២៤ (លានដុល្លារអាម៉េរិក)

| សូចនាករ | ២០២២ | ២០២៣ | ២០២៤ | ២០២៤ | | | Δ% | | |
|---|---|---|---|---|---|---|---|---|---|
| | ៣ខែ | ៣ខែ | ៣ខែ | មករា | កុម្ភៈ | មីនា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៣ខែ) |
| **តម្លៃនាំចេញសរុប (I)** | **5,717** | **5,392** | **6,317** | **1,984** | **2,041** | **2,291** | **12.2%** | **8.8%** | **17.2%** |
| **តម្លៃនាំចេញសរុប (ដកមាសចេញ)** | **5,632** | **5,307** | **6,262** | **1,967** | **2,018** | **2,276** | **12.8%** | **10.6%** | **18.0%** |
| វាយនភណ្ឌ និងស្បែកជើង | 3,104 | 2,402 | 2,898 | 966 | 929 | 1002 | 7.9% | 17.7% | 20.6% |
| កង់ | 231 | 142 | 69 | 21 | 21 | 27 | 29.9% | -54.3% | -51.5% |
| អង្ករ | 105 | 126 | 134 | 33 | 33 | 69 | 108.9% | 28.6% | 6.4% |
| ដំឡូងមី | 332 | 340 | 422 | 176 | 137 | 109 | -20.1% | -3.7% | 23.9% |
| ជ័រកៅស៊ូ | 103 | 93 | 128 | 65 | 37 | 26 | -28.6% | -13.5% | 37.0% |
| ទំនិញផ្សេងៗ | 1,757 | 2,204 | 2,611 | 707 | 862 | 1043 | 20.9% | 9.7% | 18.5% |
| **តម្លៃនាំចូលសរុប (II)** | **7,446** | **5,860** | **6,389** | **2,177** | **2,100** | **2,113** | **0.6%** | **-8.0%** | **9.0%** |
| **តម្លៃនាំចូលសរុប (ដកមាសចេញ)** | **6,165** | **5,860** | **6,235** | **2,090** | **2,045** | **2,100** | **2.7%** | **-8.6%** | **6.4%** |
| ក្រណាត់ | 1,289 | 1,026 | 1,129 | 399 | 369 | 361 | -2.1% | -18.6% | 10.0% |
| គ្រឿងសំណង់ | 472 | 417 | 513 | 183 | 174 | 155 | -10.8% | -1.2% | 22.9% |
| យានយន្ត | 310 | 283 | 279 | 57 | 118 | 103 | -12.7% | -0.9% | -1.7% |
| ប្រេងឥន្ធនៈ | 581 | 584 | 722 | 232 | 253 | 236 | -6.8% | 22.9% | 23.5% |
| ទំនិញផ្សេងៗទៀត | 3,514 | 3,548 | 3,593 | 1,219 | 1,131 | 1,244 | 10.0% | -11.2% | 1.3% |
| **តុល្យភាពពាណិជ្ជកម្ម (I-II)** | **-1,729** | **-468** | **-73** | **-193** | **-58** | **178** | | | |

*ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*

*សម្គាល់៖ ក្នុងតារាង (,)ស្មើកាត់ខ្ទង់ និង (.)ស្មើក្បៀស*

## ៣.១.៣. ស្ថានភាពវិនិយោគ / Investment

| តារាង ៣.១.៣៖ ស្ថានភាពវិនិយោគក្នុងខែមីនា ឆ្នាំ២០២៤ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករ | ឯកតា | ២០២៣ | ២០២៣ ៣ខែ | ២០២៤ ៣ខែ | ២០២៤ | | | Δ% | | |
| | | | | | មករា | កុម្ភៈ | មីនា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៣ខែ) |
| ចំនួនគម្រោង | គម្រោង | 268 | 39 | 106 | 32 | 37 | 37 | 0 | 29 | 67 |
| ចំនួនទុនវិនិយោគ | លាន($) | 4,927.6 | 294.0 | 2,203.6 | 187.06 | 1,198.67 | 817.90 | -31.8% | 1158.0% | 649.5% |
| ចំនួនការងារបង្កើត | ពាន់នាក់ | 307,553 | 46,807 | 107,100 | 28,833 | 38,345 | 39,922 | 4.1% | 482.2% | 128.8% |

*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

*សម្គាល់៖ ១) *គិតជាចំនួនគម្រោង ២)ក្នុងតារាង (,)ស្មើកាត់ខ្ទង់ និង (.)ស្មើក្បៀស*

## ៣.១.៤. ស្ថានភាពទេសចរណ៍ / Tourism

| តារាង ៣.១.៤៖ ចំនួនភ្ញៀវអន្តរជាតិក្នុងខែមីនា ឆ្នាំ២០២៤ (ពាន់នាក់) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សូចនាករសំខាន់ៗ | ២០២៣ | ២០២៣ ៣ខែ | ២០២៤ ៣ខែ | ២០២៤ | | | Δ% | | |
| | | | | មករា | កុម្ភៈ | មីនា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៣ខែ) |
| **សរុប** | 5,453.53 | 1,292 | 1,583 | 540 | 449 | 594 | 32.4% | 30.8% | 22.5% |
| តាមអាកាស | 1,866.23 | 482 | 642 | 207 | 213 | 222 | 4.0% | 32.7% | 33.3% |
| ប្រកអន្តរជាតិភ្នំពេញ | 1,365.74 | 339 | 431 | 133 | 142 | 156 | 9.7% | 29.4% | 27.1% |
| ប្រកសៀមរាប | 484.74 | 138 | 207 | 72 | 70 | 65 | -6.8% | 44.2% | 49.8% |
| ប្រកកងកេង | 15.75 | 4 | 4 | 1 | 1 | 1 | -31.7% | -39.6% | -13.8% |
| **តាមផ្លូវគោកនិងទឹក** | 3,587.00 | 810 | 941 | 334 | 235 | 372 | 58.3% | 29.7% | 16.2% |
| ផ្លូវគោក | 3,520.73 | 792 | 908 | 324 | 222 | 362 | 63.2% | 29.0% | 14.6% |
| ផ្លូវទឹក | 66.27 | 18 | 33 | 10 | 13 | 10 | -25.9% | 67.8% | 87.2% |
| **ទេសចរបរទេសចូលទស្សនារមណីយដ្ឋានអង្គរ** | 798.07 | 236 | 348 | 116 | 120 | 112 | -7.2% | 40.7% | 47.0% |

*ប្រភព៖ ក្រសួងទេសចរណ៍*

*សម្គាល់៖ ក្នុងតារាង (,)ស្មើកាត់ខ្ទង់ និង (.)ស្មើក្បៀស*

## ៣.១.៥. ស្ថានភាពសំណង់ / Construction

| តារាង ៣.១.៥៖ ស្ថានភាពសំណង់ក្នុងខែមីនា ឆ្នាំ២០២៤ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករ | ឯកតា | ២០២៣ | ២០២៣ ៣ខែ | ២០២៤ ៣ខែ | ២០២៤ | | | Δ % | | |
| | | | | | មករា | កុម្ភៈ | មីនា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៣ខែ) |
| សរុបចំនួនគម្រោង * | ចំនួន | 3,207 | 1,023 | 830 | 214 | 235 | 256 | 21 | 19 | -193 |
| សរុបជាផ្ទៃក្រឡា | ពាន់ម$^{២}$ | 13,132 | 3,046 | 1,987 | 736 | 812 | 439 | -46% | -65% | -35% |
| សរុបជាទឹកប្រាក់ | លាន | 5,461 | 1,284 | 787 | 296 | 305 | 186 | -39% | -62% | -39% |

*ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

*សម្គាល់៖ ១) *គិតជាចំនួនគម្រោង ២)ក្នុងតារាង (,)ស្មើកាត់ខ្ទង់ និង (.)ស្មើក្បៀស*

## ៣.២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity Prices

| តារាង ៣.២.១៖ ស្ថានភាពថ្លៃទំនិញសំខាន់ៗ (ថ្លៃមធ្យមប្រចាំខែ) | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករសំខាន់ៗ | | ឯកតា | ២០២៣ | | | ២០២៤ | | | ∆ % | |
| | | | មករា | កុម្ភៈ | មីនា | មករា | កុម្ភៈ | មីនា | ខែមុន | ឆ្នាំមុន |
| ក្នុងស្រុក | សាំងធម្មតា | រៀល/លីត្រ | 4,267 | 4,417 | 4,250 | 4,167 | 4,333 | 4,300 | -0.8% | 1.2% |
| | ម៉ាស៊ូត | រៀល/លីត្រ | 4,517 | 4,433 | 4,167 | 4,133 | 4,267 | 4,167 | -2.3% | 0.0% |
| | ហ្គាស | រៀល/១៥គ.ក្រ | 75,800 | 75,800 | 76,580 | 75,763 | 76,500 | 76,300 | -0.3% | -0.4% |
| | អង្ករផ្កាម្លិះ | រៀល/គី.ក្រ | 3,627 | 3,639 | 3,667 | 3,837 | 3,896 | 3,803 | -2.4% | 3.7% |
| | អង្ករផ្កាខ្ញី | រៀល/គី.ក្រ | 2,634 | 2,650 | 2,676 | 3,341 | 3,381 | 3,342 | -1.2% | 24.9% |
| | អង្ករនាងមិញ | រៀល/គី.ក្រ | 2,818 | 2,825 | 2,841 | 2,999 | 2,968 | 2,971 | 0.1% | 4.6% |
| អន្តរជាតិ | Average Oil Price | ដុល្លារ/បារ៉ែល | 80.41 | 80.25 | 76.47 | 77.67 | 80.55 | 83.55 | 3.7% | 9.2% |
| | Brent | ដុល្លារ/បារ៉ែល | 83.09 | 82.71 | 78.53 | 80.23 | 83.76 | 85.45 | 2.0% | 8.8% |
| | Dubai | ដុល្លារ/បារ៉ែល | 80.03 | 81.21 | 77.52 | 78.86 | 81.18 | 84.70 | 4.3% | 9.3% |
| | WTI | ដុល្លារ/បារ៉ែល | 78.11 | 76.84 | 73.37 | 73.93 | 76.70 | 80.49 | 4.9% | 9.7% |
| | អង្ករថៃ (៥%) | ដុល្លារ/តោន | 517.00 | 492.00 | 476.00 | 660.00 | 624.00 | 613.00 | -1.8% | 28.8% |
| | អង្ករវៀតណាម (៥%) | ដុល្លារ/តោន | 440.66 | 448.28 | 444.64 | 625.51 | 614.26 | 585.43 | -4.7% | 31.7% |
| | អង្ករថៃ (២៥%) | ដុល្លារ/តោន | 507.00 | 482.00 | 468.00 | 620.00 | 594.00 | 584.00 | -1.7% | 24.8% |
| | អង្ករថៃ A.1 (100%) | ដុល្លារ/តោន | 484.64 | 468.95 | 460.91 | 648.86 | 619.90 | 607.72 | -2.0% | 31.9% |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (NIS), ក្រសួងពាណិជ្ជកម្ម, World Bank, អ.គ.ប.*

## ៣.២.២ ស្ថានភាពថ្លៃប្រេងឥន្ធនៈនៅប្រទេសកម្ពុជា

**តារាង ៣.២.២ ថ្លៃលក់រាយប្រេងឥន្ធនៈនៅប្រទេសកម្ពុជា (ថ្លៃមធ្យមប្រចាំខែ និងប្រចាំឆ្នាំ)**

| ឈ្មោះទំនិញ | ឯកតា | ថ្លៃលក់រាយ (ថ្លៃមធ្យមប្រចាំឆ្នាំ) | | | | | | ថ្លៃលក់រាយ (ថ្លៃមធ្យមប្រចាំខែ) ៦ខែចុងក្រោយ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ៣ខែ ដើមឆ្នាំ ២០២៤ | តុលា ២០២៣ | វិច្ឆិកា ២០២៣ | ធ្នូ ២០២៣ | មករា ២០២៤ | កុម្ភៈ ២០២៤ | មីនា ២០២៤ |
| សាំងធម្មតា | រ/លីត្រ | 3,623 | 3,000 | 3,888 | 4,800 | 4,330 | 4,300 | 4,400 | 4,333 | 4,200 | 4,167 | 4,333 | 4,300 |
| ប្រេងម៉ាស៊ូត | រ/លីត្រ | 3,504 | 2,768 | 3,508 | 5,115 | 4,296 | 4,186 | 4,717 | 4,383 | 4,183 | 4,133 | 4,267 | 4,167 |
| ប្រេងឥន្ធនៈជាមធ្យម | រ/លីត្រ | **3,564** | **2,884** | **3,698** | **4,958** | **4,313** | **4,243** | **4,558** | **4,358** | **4,192** | **4,150** | **4,300** | **4,233** |

**បម្រែបម្រួលថ្លៃប្រេងឥន្ធនៈនៅប្រទេសកម្ពុជា (រៀល/លីត្រ) និង (%)**

| ឈ្មោះទំនិញ | ឯកតា | បម្រែបម្រួលថ្លៃប្រេងឥន្ធនៈប្រចាំឆ្នាំ (រៀល/លីត្រ) និង (%) | | | | | | បម្រែបម្រួលថ្លៃប្រេងឥន្ធនៈប្រចាំខែ (រៀល/លីត្រ) និង (%) (៦ខែចុងក្រោយ) | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ៣ខែ ដើមឆ្នាំ ២០២៤ | តុលា ២០២៣ | វិច្ឆិកា ២០២៣ | ធ្នូ ២០២៣ | មករា ២០២៤ | កុម្ភៈ ២០២៤ | មីនា ២០២៤ |
| សាំងធម្មតា | រ/លីត្រ | - | -623 | +888 | +913 | -470 | -30 | -250 | -67 | -183 | -33 | +167 | -33 |
| | % | - | -17.19% | +29.58% | +23.47% | -9.80% | -.69% | -5.38% | -1.52% | -4.18% | -.79% | +4.0% | -.77% |
| ប្រេងម៉ាស៊ូត | រ/លីត្រ | - | -736 | +740 | +1,607 | -819 | -110 | -67 | -333 | -150 | -50 | +133 | -100 |
| | % | - | -21.01% | +26.75% | +45.80% | -16.02% | -2.55% | -1.39% | -7.07% | -3.46% | -1.20% | +3.23% | -2.34% |
| ប្រេងឥន្ធនៈជាមធ្យម | រ/លីត្រ | - | -680 | +814 | +1,260 | -645 | -70 | -158 | -200 | -167 | -42 | +150 | -67 |
| | % | - | -19.07% | +28.22% | +34.06% | -13.01% | -1.62% | -3.36% | -4.39% | -3.82% | -0.99% | +3.61% | -1.55% |

*ប្រភព៖ ក្រសួងពាណិជ្ជកម្ម*

# ៣.២.៣ ស្ថានភាពថ្លៃឆៅនៅលើទីផ្សារអន្តរជាតិ

| តារាង ៣.២.៣ ថ្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ (ថ្លៃមធ្យមប្រចាំខែ និងប្រចាំឆ្នាំ) | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះទំនិញ | ឯកតា | ថ្លៃមធ្យមប្រចាំឆ្នាំ | | | | | | ថ្លៃមធ្យមប្រចាំខែ ៦ខែចុងក្រោយ | | | | | |
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ៣ខែ ដើមឆ្នាំ ២០២៤ | តុលា ២០២៣ | វិច្ឆិកា ២០២៣ | ធ្នូ ២០២៣ | មករា ២០២៤ | កុម្ភៈ ២០២៤ | មីនា ២០២៤ |
| ប្រេងឆៅ (Brent) | $/បារ៉ែល | 64.03 | 42.3 | 70.44 | 99.82 | 82.62 | 83.15 | 91.06 | 83.18 | 77.86 | 80.23 | 83.76 | 85.45 |
| ប្រេងឆៅ (WTI) | $/បារ៉ែល | 57.01 | 39.31 | 67.96 | 94.43 | 77.67 | 77.04 | 85.57 | 77.43 | 72.08 | 73.93 | 76.70 | 80.49 |
| ប្រេងឆៅ (Dubai) | $/បារ៉ែល | 63.18 | 42.17 | 68.81 | 97.05 | 81.98 | 81.58 | 90.62 | 83.45 | 77.22 | 78.86 | 81.18 | 84.70 |
| ប្រេងឆៅជាមធ្យម | $/បារ៉ែល | 61.41 | 41.26 | 69.07 | 97.10 | 80.76 | 80.59 | 89.08 | 81.35 | 75.72 | 77.67 | 80.55 | 83.55 |

| បម្រែបម្រួលថ្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ (ដុល្លារ/បារ៉ែល) និង (%) | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះទំនិញ | ឯកតា | បម្រែបម្រួលថ្លៃប្រេងឥន្ធនៈប្រចាំឆ្នាំ (ដុល្លារ/បារ៉ែល) និង (%) | | | | | | បម្រែបម្រួលថ្លៃប្រេងឥន្ធនៈប្រចាំខែ (ដុល្លារ/បារ៉ែល) និង (%) (៦ខែចុងក្រោយ) | | | | | |
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ៣ខែ ដើមឆ្នាំ ២០២៤ | តុលា ២០២៣ | វិច្ឆិកា ២០២៣ | ធ្នូ ២០២៣ | មករា ២០២៤ | កុម្ភៈ ២០២៤ | មីនា ២០២៤ |
| ប្រេងឆៅ (Brent) | $/បារ៉ែល | - | -21.73 | +28.14 | +29.38 | -17.21 | +0.53 | -3.14 | -7.88 | -5.33 | +2.37 | +3.54 | +1.68 |
| | % | - | -33.94% | +66.53% | +41.71% | -17.24% | +.64% | -3.40% | -8.65% | -6.40% | +3.04% | +4.41% | +2.01% |
| ប្រេងឆៅ (WTI) | $/បារ៉ែល | - | -17.71 | +28.66 | +26.47 | -16.76 | -0.63 | -2.94 | -8.14 | -5.35 | +1.85 | +2.77 | +3.79 |
| | % | - | -31.05% | +72.90% | +38.94% | -17.75% | -.81% | -3.13% | -9.51% | -6.91% | +2.57% | +3.75% | +4.94% |
| ប្រេងឆៅ (Dubai) | $/បារ៉ែល | - | -21.01 | +26.64 | +28.24 | -15.07 | -0.40 | -2.46 | -7.17 | -6.23 | +1.64 | +2.32 | +3.52 |
| | % | - | -33.26% | +63.18% | +41.05% | -15.53% | -.49% | -2.64% | -7.91% | -7.47% | +2.12% | +2.94% | +4.34% |
| ប្រេងឆៅជាមធ្យម | $/បារ៉ែល | - | -20.15 | +27.81 | +28.03 | -16.35 | -0.17 | -4.01 | -7.73 | -5.64 | +1.95 | +2.88 | +3.00 |
| | % | - | -32.81% | +67.41% | +40.58% | -16.83% | -.21% | -4.48% | -8.68% | -6.93% | +2.58% | +3.70% | +3.72% |

*ប្រភព៖ ធនាគារពិភពលោក (The Pink Sheet)*